«ខ្ញុំអរគុណហើយ ដែលបងឯងព្រមបរិច្ចាគក្រលៀនឱ្យវា ! តែ....តាមពិត បើខ្ញុំមាំដូចបងឯង ខ្ញុំក៏ធ្វើដូចគ្នា មិនឱ្យបងឯងលំបាកទេ»

សម្តីម៉ាចនៅលើជណ្តើរពេលនេះ ឬកាំបិតពេទ្យទាំងអស់នៅទីនេះផង ក៏នឹងមិនមានអានុភាពអ្វី មកធ្វើឱ្យខ្ញុំឈឺចាប់ ឬមួយក៏អាចធ្វើឱ្យបេះដូងរបស់ខ្ញុំរង្គោះរង្គើដោយការភ័យព្រួយទៀតនោះទេ ប្រហែលជាដោយសារបេះដូងនេះ ធ្លាប់រងរបួស ឈឺច្រើនដងពេកទៅហើយ បានជាវាស៊ាំទៅនឹងការឈឺចាប់បាន។

ខ្ញុំបិទភ្នែក ធ្វើមិនឮ ព្រោះមិនចង់ឆ្លើយ ប៉ុន្តែការបិទភ្នែករបស់មនុស្សយើង មិនអាចរំលត់ទៅ នូវអ្វីដែលយើងបានចងចាំក្នុងប្រព័ន្ធចងចាំខួរក្បាលខ្មៅកុំរ៉ែមួយនេះឡើយ។

«បងឯងត្រូវរកល្បិច ឱ្យវាគិតថាបងឯងមិនបានស្រលាញ់វា! ធ្វើយ៉ាងណាក៏ដោយឱ្យវាព្រមរៀបការជាមួយខ្ញុំ ព្រោះបងឯងមើលចុះ ខ្ញុំមានចំណេះដឹង មានកេរឈ្មោះ ខ្ញុំអាចថែទាំវាបានល្អជាងបងឯង!»

ការប្រគល់មនុស្សស្រីដែលយើងស្រលាញ់ ហើយដែលនាងបានសន្យាថា ស្រលាញ់យើងតែម្នាក់គត់ ទៅឱ្យមនុស្សម្នាក់ទៀត ព្រោះតែហេតុផល«ស័ក្តិសមគ្នា»ក្នុងសង្គមវាដូចជា បុកមួយចុងដែកដុត មកចំកណ្តាលទ្រូង។ ដំបៅនេះ ផ្សា ក្តៅស៊ីរូង គ្មានថ្ងៃជានោះឡើយ។

មែនហើយ! កាលយប់នោះខ្ញុំផឹកដេកដួល  ព្រោះខឹងអាម៉ាចដែលមកស្នើសុំបេះដូងខ្ញុំយកទៅកាប់ចិញ្ច្រាំ  ដូចវាកំពុងយកកាំបិតមកចាក់ទ្រូងមនុស្សម្នាក់ ដែលធ្លាប់ដឹកដៃវាទៅសាលារៀន និងមកឱ្យគេប្រើដូចគោក្របី ដើម្បីតែបាននៅក្បែរនិងលួងលោមវាឱ្យព្រមឆ្លងបពិបាកលេបនៅមណ្ឌលក្មេងកំព្រា ដើម្បីគ្រាន់នឹងរស់បានបន្តជីវិត។

ខ្ញុំខឹងវា ព្រោះវា រៀនបានចេះដឹងជាងគេក្នុងចំណោមក្មេងអនាថាមកពីភូមិយើង តែចិត្តវាសាហាវគ្មានមេត្តា ស្មើឆ្កែចចកមួយក្បាល។ ខ្ញុំខឹងវា តែនៅខឹងតិចជាងពិភពលោកក្លែងក្លាយនិងសែនអាត្មានិយមមួយនេះ ដែលបានកែប្រែអាម៉ាចឱ្យទៅជាអ្វីដែលយើងកំពុងឃើញ។

ទោះបីថា សំណើវា គឺជារឿងដ៏គួរឱ្យស្អប់ខ្ពើមមួយ ខ្ញុំក្រោកចង្អុលមុខវាហើយលើកតុស្រាក្រឡាប់ចោល ជាសញ្ញាថា«កុំឱ្យអញឃើញមុខឯងទៀត» តែត្រឡប់មកផ្ទះដួលវិញ ខ្ញុំចាប់ផ្តើមសម្លឹងឃើញរូបខ្លួនឯងក្នុងកញ្ចក់។ ក៏មានហេតុផលជាច្រើន ដែលខ្ញុំគួរយកមកថ្លឹងថ្លែងដែរ។ តើអាមីនសមនឹងខ្ញុំដែរអត់?  ហេតុផលអីគេ ត្រូវមកផ្សារភ្ជាប់ជីវិត ជាមួយមនុស្សដូចខ្ញុំ សូម្បីតែផ្កាស្លា តើខ្ញុំមានលទ្ធភាពលើកជូននាងដែរទេ ខណៈដែលមនុស្សម្នាក់ទៀត ដែលបានស្គាល់នាងទាំងអតីតកាលគ្រប់

យ៉ាង ទាំងអស់របស់នាង ទំនាក់ទំនងស្នេហានាងហើយនិងខ្ញុំ ក៏គេនៅតែត្រូវការនាង ហើយមាន អាចឃុំគ្រងថែទាំនាងបាន ហេតុអ្វីខ្ញុំមិនដោះលែងនាងទៅ។

«អ្នកអាត្មានិយមគឺបងឯង! កុំស្មានខ្ញុំមិនដឹង ដែលបងឯងកាលឆ្នាំនោះឱ្យវាទៅអ្នកមានយកទៅចិញ្ចឹមព្រោះបងឯងយល់ថា ពង្វក់វាបាន ហើយបងឯងដឹងថាមិនអាចបង្វិលក្បាលខ្ញុំបាន!»

សម្តីអាម៉ាចម្តងៗ ប្រៀបដូចជាថ្នាំពុលមួយស្លាបព្រា ដែលអាចឱ្យខ្ញុំពុលហើយពុលទៀត ងើបមុខមិនរួច ក្លាហានមិនកើតក្នុងការប្រឈមនឹងការពិតដ៏ឈឺចាប់ចំពោះមុខមួយនេះ។

ស្នេហារវាងគេ អាមីនហើយនិងខ្ញុំបានចប់ទៅ នៅពេលដែលខ្ញុំសម្រេចចិត្តថា «ចប់!»

«មនុស្សល្អដូចគេ បើបងឯងស្រលាញ់គេ បងឯងចាកចេញពីគេទៅ! ហើយដើម្បីចាកចេញពីគេបានសម្រេច ទាល់តែធ្វើឱ្យគេស្អប់បងឯង!» ម៉ាចបង្គាប់ខ្ញុំ។

វាមិនពិបាកទេ នៅក្នុងការធ្វើឱ្យនរណាម្នាក់ស្អប់យើង ដែលពិបាកគឺ យើងត្រូវមកស្អប់មនុស្សដែលយើងធ្លាប់ហៅថាប្អូន ហើយកំពុងសម្លាប់យើងនៅក្នុងចំណងមនោសញ្ចេតនាមួយនេះ។

«ឯងមិនយកទាំងជីវិតអញតែម្តងទៅ!»

«គិតឡើងវិញបង! មិនមែនខ្ញុំមិនគិតបងឯងទេ! តែបងឯងគិតថារឿងបងឯងនិងអាមីនទៅរួចបានត្រឹមណា? មុននិងក្រោយតែប៉ុណ្ណឹងបង!»

ខ្ញុំបានយល់ព្រមដោយស្ម័គ្រចិត្ត ក្នុងការចាកចេញពីសេចក្តីស្នេហាមួយនេះ ស្មើនឹងចាកចេញពីសេចក្តីស្រលាញ់មួយដែលធ្លាប់បានចាប់ផ្តើមឡើងដោយនិស្ស័យពីព្រេង និងបញ្ចប់ទៅទាំងមិនទាន់អស់ចិត្ត។ ទោះយ៉ាងណា អាម៉ាចនិយាយត្រូវ បញ្ចប់ទៅនៅពេលនេះ វាប្រសើរជាងយើងនៅមានៈទៅបំផ្លាញអនាគតរបស់គេ ហើយចុងក្រោយគង់តែបែកបាក់គ្នាដោយសារភាពខុសគ្នារបស់យើងនៅក្នុងសង្គម។

«ឯងសន្យាមើលវាឱ្យល្អ! វាធ្វើខុសឬត្រូវ ហាមឯងប្រើដៃជើងលើវាដាច់ខាត! សុខភាពវាខ្សោយ ឯងធ្វើការសំខាន់យ៉ាងណាក្តី ត្រូវលៃទុកពេលមកមើលវា ថ្នមចិត្តវា! វាចង់បានអីត្រូវឯងរកមកឱ្យវាផ្គាប់ចិត្តវា»

ខ្ញុំនិយាយចុងក្រោយជាមួយអាម៉ាច មុនពេលស្បថថា ជាតិនេះមិនចង់ជួបមុខពីរនាក់វាទៀតឡើយ។

ទំនាក់ទំនងរវាងបុគ្គល២នាក់ មិនមែនសុទ្ធតែជាសេចក្ដីស្នេហានោះឡើយ ហើយបើទោះនេះជាស្នេហា និងកាលណោះ បងបានសន្យាថា តទៅត្រូវមើលថែអូន តែគ្រប់យ៉ាង រមែងមានហេតុផលរបស់វា បងសូមទោសដែលមិនអាចធ្វើតាមសន្យា។

ចាកចេញពីទីក្រុងភ្នំពេញមកនៅកំពង់ចាមវិញ ជាមួយម្ដាយជរារបស់ខ្ញុំ ហើយតាំងចិត្តថានឹងរកប្រពន្ធមួយ ឋានៈ ចំណេះដឹង ចំណូលប្រហាក់ប្រហែលគ្នា ហើយកសាងជីវិតថ្មីបំភ្លេចរឿងទាំងថ្មីទាំងចាស់នៅភ្នំពេញ។ ទោះយ៉ាងណា ខ្ញុំធ្វើរឿងនេះមិនដែលបានសម្រេចទេ ខ្ញុំមិនអាចរកបានមនុស្សណាម្នាក់មកជំនួសគេឡើយ ក្នុងជីវិតសេសសល់នេះ។

រំលងពីអវត្តមានខ្ញុំ៧ខែ អាម៉ាចបានរៀបការជាមួយនាងតាមវិធីសាស្ត្រដែលវារកនឹកឃើញ ពិសេសការផ្គាប់ផ្គុនឪពុកធម៌ចូលជរារបស់នាង។

នោះជាថ្ងៃអ្វីទៅ? ខ្ញុំគួរតែសប្បាយចិត្តនឹងមានសេចក្ដីសុខបំផុត ប្រៀបដូចជាបងប្រុសម្នាក់បានឃើញប្អូនប្រុសនិងប្អូនស្រីរបស់ខ្លួនចូលរោងការដូច្នោះដែរ។ ផ្លូវថ្នល់ក្រាលដោយផ្កាសុភមង្គលនៅពីមុខពួកគេ យើងឮហើយគួរតែភ្លេចអំពីទុក្ខវេទនាក្នុងបេះដូងខ្លួនឯងចោល ព្រោះខ្ញុំមិនបានប្រើប្រាស់អាមីនដូចវាគិតទេ ខ្ញុំក៏មិនមែនមនុស្សប្រុសអាត្មានិយមដូចវាយល់ដែរ។

បើត្រូវនៅសល់តែម្នាក់ឯងឯកោ នៅក្នុងពិភពលោកយើងនេះ ខ្ញុំក៏អាចធ្វើបាន ប៉ុន្តែប្អូនប្រុសខ្ញុំមិនត្រឹមចង់បានប៉ុណ្ណឹង វាថែមទាំងចង់ ឱ្យអតីតកាលទាំងអស់រលុបរលាយទៅតាមការបាត់ខ្លួនរបស់ខ្ញុំដែរ។ ដូច្នេះហើយនៅក្រោយការរៀបការរបស់វាជាងមួយឆ្នាំ វាបញ្ជូនមនុស្សមួយក្រុមមកយាយីខ្ញុំ។ រយៈពេលដែលវាក្លាយជាអ្នកមានធំ ជំនួសតំណែងឪពុកក្មេកវា វាអន់ចិត្តណាស់ដែលមានអ្នកយករូបថតយើងទាំងបីនៅមណ្ឌលក្មេងកាលណោះ ទៅប្រគល់ឱ្យអ្នកកាសែត។ យើងមិនដឹងថាអ្នកធ្វើមានបំណងអី ជាអ្នកណាទេ តែវាបែរជាយល់ថាខ្ញុំតាមយាយីមុខមាត់ព្រោះច្រណែនឈ្នានីសវា។

មនុស្សមានពុតត្បុត និងមានចិត្តជាកលខ្លួនឯង តែងតែគិតឃើញរិះគន់ ឬមន្ទិល លើសន្ដានចិត្តស្មោះសរនៃអ្នកដទៃ។ តួយ៉ាងមនុស្សជាអ្នកលេងបួនប្រាំនាក់ ដែលវាបានបញ្ជូនឱ្យមកដាល់វាយដំខ្ញុំបញ្ចេញកំហឹងដល់ផ្ទះ បានបង្ហាញស្រេចហើយថា មនុស្សដូចវា ទោះរុំព័ទ្ធដោយលុយវាល់លានឬពាក់មួកជាបណ្ឌិត តែគុណធម៌សូន្យរបស់វា នឹងធ្វើឱ្យវាអន់ជាងសត្វសុនក ដែលហោចណាស់ចេះព្រុស បក់កន្ទុយដឹងគុណ ជាងមារយាទរបស់អាម៉ាចដែរ។

ក្រោយពីប្រដៅក្មេងក្មាងវាអស់ហើយ ខ្ញុំបានផ្ដាំតាមពួកនោះថា មុនក្រោយខ្ញុំគង់តែឡើងទៅរកវាដល់ភ្នំពេញទេ។

មិនយូរប៉ុន្មានខ្ញុំបានព័ត៌មានតាមទស្សនាវដ្ដីថា គ្រួសារវាមិនចុះសម្រុង ហើយអាមីនបានប្រុងសម្លាប់ខ្លួនត្រូវអ្នកផ្ទះជួយទាន់។

ខ្ញុំទៅចាំជួបវាដល់ចំណតឡានទំនើបក្រោមក្រុមហ៊ុន។ អាម៉ាចចុះមកទាំងញ៉ៀងញ៉ងជាមួយលេខាស្រីស្អាតសិចស៊ីរបស់វា។ បណ្ឌិតនេះស្រឡាំងកាំងប្រុងគេចពីខ្ញុំដែរ តែជំហានវាទៅឆ្វេងស្ដាំណាក៏ខ្ញុំដឹង មានអីឆ្ងល់ ជីវិតវានេះ ខ្ញុំជាអ្នកផ្ទុងផ្ដើមឡើងមក សម្ដីវាចង់ហាមួយម៉ាត់ណា ក៏ខ្ញុំដឹងដល់កន្ទើតដែរ គ្រាន់តែខ្ញុំមិនចេះធ្វើជាមនុស្សថ្នាន់គេ។ ខ្ញុំចង្អុលឱ្យលេខាវាចាកចេញ ព្រោះមិនចង់វាយគ្នាមុខស្រីៗ។ បានដូចចិត្ត មនុស្សដែលហែហមវាព្រោះលុយ បានត្រឹមប្រជ្រៀតគ្នាមករួមសុខ តែមិនបាននៅរួមទុក្ខជាមួយវាទេ។ វាខំរត់ទៅឡាន ដែរតែខ្ញុំរហ័សជាងវា ខ្ញុំក្របួចកវាពីក្រៅឡានហើយអូសទាញរហូតដល់វាព្រមចុះមកដីវិញ។

ជាលើកដំបូងដែលខ្ញុំ ដាល់វាម៉ាំងមួយទំហឹងកូនប្រុសបែកឈាមកក្លាក់។

«លើកនេះ អញឱ្យអ្អែងប៉ុណ្ណឹង ហើយដែលមិនធ្វើអីឯងធ្ងន់ មិនមែនអញចិត្តទន់ម្ដងទៀតទេអាម៉ាច! ព្រោះអញគិតដល់គេ! បើម្ដងទៀត អ្អែងធ្វើបាបគេ ហើយអញដឹង អ្អែងកុំសង្ឃឹមរត់រួចអាម៉ាច!»

ខ្ញុំជូតទឹកសម្បោរ ទឹកភ្នែកដែលល្វង់ខ្លៅ ជូរចត់ ឈឺចាប់ ស្រក់រសើបក្នុងបេះដូង ពេលឃើញដៃខ្លួនឯងបង្កស្នាមរបួសលើមុខបណ្ឌិត ដែលខ្ញុំធ្លាប់បីបាច់រក្សា ងូតទឹកឱ្យ រត់លេងប្រលែង ចំណីមួយម៉ាត់មិនរំលងមាត់។ ជាទំហំកម្លាំងមុតនៃការ«ឈឺ»ខ្លាំងជាងស្នាមកាំបិតដែលធ្លាប់ចារទុកមក សុសលើខ្នងកូនប្រុសអ្នកក្រម្នាក់នេះ។

ពាក្យថា «បង» រវាងវាហើយនិងខ្ញុំ ពីនេះតទៅ «ចប់ហើយ!» នេះជាលើកចុងក្រោយដែលខ្ញុំអត់ទោសឱ្យវា «ព្រោះតែគុណលុយកាក់ដែលវាធ្លាប់ទិញថ្នាំឱ្យម្ដាយខ្ញុំ និងកន្សែងស្អំកម្ដៅ ដែលវាធ្លាប់រុំក្បាលឱ្យខ្ញុំ» ខ្ញុំសងវាចប់។

យើងចប់គ្នាហើយអាម៉ាច «អញបានសងឯង សូម្បីតែមនុស្សស្រីម្នាក់ ដែលអញធ្លាប់គិតថា ជាតិនេះមិនអាចរស់គ្មានគេបាន អាប្អូនចង្រៃ ទុកថាយើងទាំងបីមិនដែលស្គាល់គ្នា។»

ខ្ញុំចាកចេញទាំងប្រាប់ខ្លួនឯងថា ទោះមួយជីវិតនេះ រៀនរឿងជាច្រើន ជាមួយឈាមនឹងទឹកភ្នែក តែពេលនេះតទៅ ខ្ញុំនៅត្រូវរៀនរឿងមួយទៀត គឺរៀន «ស្រលាញ់គេពីចម្ងាយ ស្រលាញ់គ្មានថ្ងៃជួប ស្រលាញ់គេទាំងសម្លាប់បេះដូងមួយនេះចោល!»

«វាមិនភ្លេចឯង! ស្រីចោលម្សៀតហ្នឹង! វាមិនព្រមភ្លេចឯងឯងទេ អាចង្រៃ ពួកឯងចង្រៃណាស់ អាចង្រៃ អ្វែងកុំមកធ្វើតួចិត្តល្អ!»

វាស្រែកយំមកពីក្រោយខ្នងខ្ញុំទាំងកំហឹង និងភាពកំសាកចោលម្សៀតរបស់វា ដែលមិនអាចធ្វើឱ្យអាមីនព្រមប្រគល់ស្នេហាឱ្យវាបាន។

ជើងខ្ញុំមិនឈប់ទេ ខ្ញុំប្រឹងដើរចេញមកទាំងបេះដូងខ្ញុំឈឺៗៗៗ.....

«វាសម្លាប់ខ្លួន មិនមែនព្រោះអញទេ! ព្រោះវា នៅស្រលាញ់ឯង! វាឆ្កួតយូរណាស់ហើយ ប្អូនស្រីចម្កួតរបស់ឯងហ្នឹង វាជាមនុស្សឆ្កួត!»

ខ្ញុំមិនចង់ស្តាប់ពាក្យ ឬហេតុផលអ្វីរបស់អាម៉ាចទៀតនោះទេ ព្រោះថា បេះដូងអើយ! ឯងស្លាប់ហើយ! ឯងបានស្លាប់បាត់ហើយតើ តាំងពីថ្ងៃឯងប្រគល់គេឱ្យប្អូនឯង ប្អូនប្រុសដែលម្តងជាពីរដងចង់តែឱ្យឯងឈឺៗៗៗៗឈឺដល់ស្លាប់! ឯងឈឺអីទៀត បើឯងគ្មានដង្ហើមផង?

«ប្រាប់វាទៅ! អញងាប់បាត់ហើយ! ពីរនាក់ឯង អញបំភ្លេចចោលយូរហើយ!»

ខ្ញុំស្រែកប្រាប់វាទាំងទឹកភ្នែកកំដរ ឈុតឆាកបងប្រុសម្នាក់នេះដែលធ្លាប់បានឱបវាទាំងពីរនាក់នៅក្រោមដើមជ្រៃក្រឹមនៃមជ្ឈមណ្ឌលកុមារកំព្រាដ៏ស្រេកឃ្លាន និងរងា។

ខ្ញុំដកអារម្មណ៍ចេញពីរឿងចាស់ ហើយសម្លឹងមុខវា ដែលកំពុងនៅពីមុខប្រមាណ១ម៉ែត្រពីគ្នា។ ខ្ញុំដឹងអ្វីដែលវាកំពុងគិត ដូច្នេះខ្ញុំបញ្ជប់ការសង្ស័យរបស់វាត្រឹមណេះ៖

«កុំភ័យ ក្រលៀនអញម្ខាងនេះ មិនទារយកអ្វីពីប្តីប្រពន្ធឯងទេ ព្រោះអាមីន វាស្លាប់បាត់យូរហើយ អស់ក្រលៀនម្ខាងមានអីអស្ចារ្យទៅ! ពេលអាមីនជាហើយ ឯងត្រូវចេញនៅស្រុកក្រៅណា មួយដែលស៊ាំល្អជាមួយសុខភាពវា ពេលនោះ ពីរនាក់ឯងក៏គ្មានបន្ទុកអតីតកាលទៀតដែរ! គ្មានអ្នកណាស្គាល់ប្រវត្តិរបស់ពួកឯងនៅជំរំជើងចាប ក៏គ្មានអ្នកណាដឹងរឿងអកតញ្ញូទាំងអស់ក្នុងស្រោមបណ្ឌិតរបស់ឯងដូចគ្នា!!»

ខ្ញុំចាកចេញពីអាម៉ាចដើររ៉ុយមកជាន់លើ។ ខុសគ្នាពីរជាន់ទៀត ខ្ញុំឡើងដល់បន្ទប់សង្គ្រោះបន្ទាន់។ បរិវេណទីនេះ គឺជាកន្លែងសម្រាកព្យាបាលដ៏ទំនើបមួយដែលខ្ញុំទើបបានឃើញនៅក្នុងជីវិតនេះ។ ប៉ុន្តែទោះបីជាកន្លែងព្យាបាលទំនើបយ៉ាងណា ក៏គ្មានអ្នកណាចង់ក្លាយជាអ្នកជំងឺឬក៏ភ្ញៀវរបស់វាដែរ។

«បន្ទប់ Z ចុងគេ បង»

«បាទ»

ខ្ញុំបានត្រឹមឆ្លើយតបខ្លីទៅកាន់គិលានុបដ្ឋាកម្នាក់ដែលខ្ញុំសួរនាំផ្លូវទៅកាន់កន្លែងអាមីន បន្ទាប់មកក៏ដើរតែឯង ឆ្ពោះតម្រង់ទៅកាន់បន្ទប់ចុងគេជួរខាងស្តាំដៃ។

បន្ទប់នេះបិទបាំងដោយបន្ទះកញ្ចក់ធំក្រាស់មួយ សឹងថាលាតសន្ធឹងពេញមួយជញ្ជាំងផ្នែកនេះ។

ប្រហែលជាគិលានុបដ្ឋាកបានទទួលបញ្ជាពីវេជ្ជបណ្ឌិតសុខៈ ប្រាប់អ្នកខាងក្នុងមុនហើយ បានជាវាំងនន ត្រូវបានបើកទុកឱ្យជាស្រេច ខ្ញុំអាចសម្លឹងទៅកាន់«គេ»បាន។

សាមីននៅតែជាអាមីនដ៏តូចច្រមក់របស់ខ្ញុំដូចកាលពីថ្ងៃដំបូងដែលយើងបានដោះដូរបេះដូងឱ្យគ្នា។ គ្រាន់តែលើកនេះ គេមិនបានញញឹមទេទៀតទេ។

យូរប៉ុនណាហើយដែលគេលែងបានញញឹម។

សូម្បីរស់នៅភូមិជើងចាប ក្រកម្សត់អត់ព្រឹកអត់ល្ងាច គេនៅតែញញឹមបានរាល់ពេលឃើញខ្ញុំដើរមក ហេតុអីពេលបានសោយទ្រព្យមហាសាលបែរជាមកគេងស្ងៀមរបៀបនេះ។

ផ្នែកខាងលើនៃគ្រែដែកទំនើប បានកល់ខ្នងរបស់គេ ទម្រេតខ្ពស់ ជាងផ្នែកត្រឹមចង្កេះចុះដល់ជើង។

«អាមីន! រឹងមាំឡើង! បន្តិចទៀត លែងពិបាកដកដង្ហើមហើយ! បងម៉ឺននៅណេះហើយ មានបងហើយមិនបាច់ខ្លាចអីទេ!»

ខ្ញុំនិយាយម្នាក់ឯងតាមទម្លាប់ដែលធ្លាប់តែនិយាយដដែលៗ រាល់ពេលពីរនាក់វាឈឺ ហើយយំព្រោះភ័យ។ អ្វីក្តីតែកាលណាធ្លាក់ចេញមកពីបេះដូងហើយ ពេលវេលាយូរយ៉ាងណាក៏មិនអាចឱ្យវារលុបទៅវិញបានដែរ។ រង្វង់មុខនេះនៅតែស្ថិតក្នុងបេះដូងរបស់ខ្ញុំជារៀងរហូតទៅ។

ពីក្នុងផ្ទាំកញ្ចក់ ដែលឃើញជះស្រមោលខ្លួនឯង ជាមួយសភាពផ្ទៃមុខក្រៀមស្រពោន ខ្ញុំដឹងថាសភាពខ្ញុំនៅមិនស្មើទៅនឹងទំហំការឈឺចាប់នៅក្នុងចិត្តពេលនេះដាច់ខាត។ ខ្ញុំតែងតែដឹងថាគេឈឺគេខ្សោយ តែនេះជាលើកដំបូង ដែលខ្ញុំឃើញគេស្តូកស្តឹងមិនដឹងខ្លួន។

ទោះគេមិនអាចញញឹមមកស្វាគមន៍ខ្ញុំទៀតបានក៏ដោយ សុំត្រឹមគេអាចញញឹមសម្រាប់ខ្លួនគេហើយក្រោកឡើងមកវិញបានដូចដើម។

«ឆាប់ក្រោកឡើង ស្រីស្អាតរបស់បង! ដឹងខ្លួនឡើង ងាកមកណ៎ា បងនៅណេះហើយ!!»

អ្វីមួយរំឭកឡើងមកវិញក្នុងអារម្មណ៍ខ្ញុំ។

ថ្ងៃមួយ ខ្ញុំកំពុងធ្វើការនៅក្នុងបារដល់ពេលយប់ ស្រាប់តែនាងបង្ហាញខ្លួនមកចំពេលខ្ញុំកំពុងប្រមូលសំរាមសែងយកទៅចោល។

 ម៉ោងជិត២ភ្លឺហើយ អាមីនមិននៅផ្ទះដេកជិតប្ដី បែរជាមកឈរក្បែរឡានទំនើបក្រហមរបស់គេសម្លឹងមកខ្ញុំ។

ទោះបីពីចម្ងាយ ប៉ុន្តែខ្ញុំដឹងថា នាងកំពុងស្រក់ទឹកភ្នែក។

«ខ្ញុំដឹងរឿងអស់ហើយ!»

នាងរត់តាមខ្ញុំដែលគេចទៅចាក់សម្រាម។

«ខ្ញុំដឹងរឿងទាំងអស់ បងឯងមិនបានស្រលាញ់ស្រីបារម្នាក់នោះ ហើយលក់ខ្ញុំយកលុយពីម៉ាចទេ តែបងឯងរួមដៃជាមួយម៉ាចកុហកខ្ញុំ ឱ្យខ្ញុំព្រមរៀបការ! ធ្វើអ៊ីចឹងធ្វើអី!»

ខ្ញុំមិនចង់និយាយស្អីនឹងនាងដោយសាររឿងវាចប់ហើយគេរៀបការរួចហើយ ចំណែកសភាពពេលនេះ គេហាក់ស្រវឹងទៀត ហើយមើលមកខ្ញុំចុះ កាន់សម្រាម ដូចកម្មករសម្រាមចាក់ម្នាក់ ។

«អាមីនទៅវិញទៅ ឈប់មកកន្លែងនេះ!»

ខ្ញុំព្រមាននាងដោយសព្ទសំឡេងខ្សោយៗហើយដើរត្រឡប់មកបារវិញដោយតឹងណែនទ្រូងពេលឃើញសភាពគេ។

ទាំងស្រវឹងផង សុខភាពដូចខ្សោយ ប្ដីគេនៅឯណាហេតុអ្វីបានជាបណ្ដោយគេឱ្យមកទីស្អុយគគ្រុកនេះ មករកខ្ញុំ?

គេរៀបការនឹងគ្នាជិតបី ឆ្នាំហើយគ្មានកូនម្នាក់សោះមិនដឹងថាមកពី ពីរនាក់នេះកាលពីក្មេងពួកគេបរិភោគមិនគ្រប់គ្រាន់ រងអំពើហិង្សាទាំងផ្លូវកាយនិងផ្លូវចិត្តឬយ៉ាងណា?

«ខ្ញុំចង់លែងលះ ហើយមកនៅក្បែរបងឯងវិញ!»

នាងនិយាយក្រង្ករៗទាំងរត់មកតាមខ្ញុំ ដោយស្បែកជើងកែងតូចស្រួចរបស់នាង។

ទីបំផុតដូចស្មាន អាមីនរត់មិនបានយូរទេ នាងអង្គុយចុះព្រោះហាត់ ហើយផ្ដើមយំយែក។

ខ្ញុំដកដង្ហើមធំ ដើរថយទៅរកនាង ហើយនិយាយផ្ទាន់ដូចហួសចិត្តខ្លាំង៖

«លុយច្រើនពេក ស្រណុកខ្លួនដល់ឡប់អស់? តស៊ូមកលំបាកម៉េចខ្លះ ទម្រាំបានដូចសព្វថ្ងៃ? កើតអផ្សុកស្អី វិមានមិនចង់ ចង់មកនៅលើគំរង់ ជាមួយអាអ្នករើសសំរាមតោកយ៉ាកនៀក? អ្ហះ?»

នាងតវ៉ាមកវិញទាំងតំអូញក្រងួរដោយគ្រឿងស្រវឹងៈ

«កើបសំរាមឱ្យគេ មានស្អីមិនល្អ? ពីណាមិនធ្លាប់កើប! កាលនៅជើងចាបកើបរាល់តែយប់! ពីណាអ្នកប្រដៅខ្ញុំថា ការងារអី ក៏មិនថោកទាបដែរ! យ៉ាងហោចណាស់....ហោចណាស់ យើងអាចធ្វើអីមួយដែលពួកអ្នកមានកម្ជិល ទម្រន់មិនហ៊ានធ្វើ! ចាំអត់? ចាំសម្ដីខ្លួនឯងអត់? អ្ហះ? និយាយហើយម៉េចមិនចាំ? អ្ហះ? ម៉េចនិយាយហើយ លេបពាក្យខ្លួនឯងចោល បងម៉ឺន!??? បងឯងថា មិនទៅណាចោលខ្ញុំ បងម៉ឺន! ពាក្យអ្នកណាថា នឹងតាមមើលសាមីន»

នាងចាប់ផ្ដើមយំសសិតពេលនិយាយដល់ត្រង់ណោះ ខណៈខ្ញុំឈរទ្រើងទាំងចុកណែន ព្រោះតែនាងរំឭកពាក្យទាំងអស់មកវិញ ដូចគ្មានបាត់មួយម៉ាត់ណា ដូចគេបានទន្ទេញគ្រប់ប្រយោគរបស់ខ្ញុំ កាលពីនៅក្មេងៗ ជាប់ក្នុងបេះដូងតរៀងមក។

«យើងមានគេតាមមើលថែហើយ! បងហត់នឹងឯងណាស់សាមីន! កុំធ្វើចរិតមើលតែមនុស្សសរសៃប្រសាទ! នឹងនរឡើង ត្រឡប់ទៅផ្ទះវិញ! ហើយឈប់មកកន្លែងនេះទៀត»

ខ្ញុំថាផង ទាញយោងនាងឡើងមកវិញផង តែនាងមិនព្រមឡើងមកទេព្រោះខឹង។ រាងកាយរបស់ខ្ញុំពីតូចដល់ប៉ុនណេះ ធ្លាប់ត្រូវគេវាយសុស ឡើងលែងខ្លាចឈឺ មុខរបស់ខ្ញុំត្រូវគេទះតប់ ចង្កេះ ត្រូវគេជាន់ សក់ត្រូវគេញីងបោច វាគ្មានអស់អីអស្ចារ្យទេ សម្រាប់ក្មេងដែលគ្មានឪពុក ឬម្ដាយក្រីក្រគ្មានលុយ គ្មានយសអំណាច។ ជីវិតនេះ ធ្លាប់ទៅហើយ ដែលដួលដេកនៅកន្លែងណាត្រដរក្រោកឡើងខ្លួនឯងវិញនៅត្រង់ណោះ។ តែអាមីន នាងមិនដូចខ្ញុំទេ។ តាំងពីអាយុ៦ឆ្នាំមក នាងមានបងប្រុសម្នាក់នេះ ជួយយោងទឹក ជួយបោសជ្រះ ជួយចាក់សម្រាម ជួយកំដរនាងលាងចានកុំឱ្យខ្លាចពេកជួយសារខោអាវជាមួយ ជួយកម្លាបណ្ដេញពួកក្មេងៗដែលមករករឿង។ ពេលនេះ ខ្ញុំនៅតែចង់ជួយយោងនាងឱ្យក្រោកឡើងមកវិញ។

មុខមាត់ដ៏ស្រស់ស្អាតរបស់អាមីន មនុស្សចិត្តស្មោះ មិនលោភលន់ មិនភ្លេចកំណើតដូចនាង  សមណាស់ហើយដែលត្រូវប្ដូរជីវិតថ្មី មានដំបូលជ្រកមិនខ្លាចរន្ទះ មិនចាំបាច់ស្ដាប់ឮរាល់សំឡេងជេរប្រទេចរបស់ម្ដាយចិញ្ចឹម មិនខ្លាចក្រពះរើឈឺព្រោះដេកអត់បាយរាល់ពេលធ្វើខុស   មិនចាំបាច់អង្គុយលាងចានមាត់ផ្លូវចិត្តភ័យខ្លាចមនុស្សស្រវឹងស្រា អ្នកសូមទាន  ឬក៏មនុស្សវិកលដោយគ្រឿងញៀន ស្ទុះមកវាយដំច្រំធាក់។

«ក្រោកឱ្យលឿនសាមីន! បងឱ្យឯងក្រោកឡើងដោយខ្លួនឯង! ក្មេងជើងចាប ម្នាក់ៗរឹងមាំណាស់ គ្មានអ្នកណាម្នាក់រំអួយមាយាទេ! ក្រោកឮអត់?!»

«មនុស្សបងឯងក្បត់សម្ដី! បងម៉ឺននៅភូមិជើងចាបជាមនុស្សគោរពសម្ដី ការពារប្អូន គាត់មិនបោះបង់ចោលប្អូនទេ! បងឯងធ្វើមុន!»

«ឯងមានប្ដីហើយនាងសាមីន! ឯងមិននៅទំនេរឱ្យបងបានមើលឯងទៀតទេ!»

«បងម៉ឺន»

សំឡេងរបស់គេលាន់មកស្រាលៗ កាត់ផ្ដាច់ខ្លួនខ្ញុំចេញពីការនឹកឃើញរឿងរ៉ាវចាស់ៗនារាត្រីមួយ ដែលការឈឺចាប់និងផ្អែមល្ហែមរួមរវាងពួកយើងបានកើតមានជាចុងក្រោយមុនពេលនាងមកដេកលើគ្រែនេះ។

ស្នូរទ្វាររបើកធ្វើឱ្យខ្ញុំមីងមាំង។

«បង! អ្នកជំងឺចង់ជួបបង!»

ខ្ញុំទីទើរ គ្រាប់ភ្នែកល្ហល្ហេវសម្លឹងទៅកាន់គិលានុបដ្ឋាយិកាជាស្ត្រីក្មេងល្ហក់ដែលទើបតែចេញពីក្នុងបន្ទប់នោះមក។ សាជាថ្មីខ្ញុំងាកទៅសម្លឹងគេឡើងវិញតាមកញ្ចក់។ ប្រហែលជាខ្ញុំរវើរវាយយូរពេកអាល័យតែលង់នឹកឃើញរឿងចាស់ៗ បានជាធ្វើឱ្យគេ ភ្ញាក់ដឹងខ្លួនឡើងមកវិញឃើញខ្ញុំ ប៉ុន្តែខ្លួនខ្ញុំមិនបានចាប់អារម្មណ៍គេ។

ពាក្យហៅខ្ញុំមុននេះ មិនអាចរំលងផ្ទាំងកញ្ចក់ក្រាស់នេះបានទេ ប្រហែលខ្ញុំស្លុងចិត្ត តែភ្នែកឃើញមាត់គេហៅខ្ញុំ។

ពេលនេះ កែវភ្នែកអំណរ ទទូច និងទុក្ខព្រួយរបស់គេ សម្លឹងត្លែរមកខ្ញុំ។

តើឱ្យខ្ញុំមានពាក្យអ្វីទៅនិយាយជាមួយគេទៅ?

«បងឯងដឹងអត់? រាល់ពេលដែលខ្ញុំអត់សប្បាយចិត្ត រាល់ពេលខ្ញុំមិនចង់រស់នៅបន្តទៀត រាល់ពេលខ្ញុំគ្មានកម្លាំងចិត្ត ខ្ញុំនឹកឃើញតែសំដីបងឯង! ពេលនោះបងឯងនៅឯណា ម៉េចបានជាបងឯងដាច់ចិត្តបោះបង់ខ្ញុំចោលឱ្យរស់នៅពិបាកម្នាក់ឯង?!»

«ឯងមានស្អីពិបាក? ឯងមានបាយស៊ី មានខោអាវស្អាតៗស្លៀកពាក់! មានគេតាមបម្រើឆ្វេងស្ដាំ! ឯងគ្រាន់តែចង្អុលដៃស្អីៗហើយជាស្រេចចំពោះមុខឯង! ហើយចង់បានស្អីទៀត?!»

«ខ្ញុំអត់ចង់បានផ្ទះធំ អត់ចង់បានពួកគេអស់នោះទេ! ឱ្យធ្វើអីក៏បានដែរ ឱ្យតែមានបងម៉ឺននៅក្បែរខ្ញុំ! ខ្ញុំអាចលាងចានប៉ុន្មានកាធុនក៏បានដែរ! ខ្ញុំអាចនៅភូមិជើងចាបមួយជីវិតទៅឱ្យតែបងឯងមកនៅក្បែរៗខ្ញុំរាល់យប់!»

នោះជាពាក្យសម្ដីចាស់ៗ នារាត្រីមួយនោះ រាត្រីចុងក្រោយមុនពេលយើងបែកគ្នាមកទល់ថ្ងៃនេះ។

មុនពេលដើរមួយៗទើបចូលទៅ ខ្ញុំលើកដៃជូតទឹកភ្នែកព្រោះតែ ខ្ញុំមិនចង់ឱ្យឃើញនាង ឃើញភាពទន់ខ្សោយនិងការឈឺចាប់ទាំងប៉ុន្មាន ដែលបានលាក់បង្កប់មកជាយូរនៅក្នុងបេះដូងរបស់ខ្ញុំនោះឡើយ។

សាមីនស្គមខ្លាំងណាស់ សឹងតែមិនមែនជានាង។

«បើសិនជាខ្ញុំមិនឈឺជិតស្លាប់ក៏បងឯងមិនមកមើលខ្ញុំដែរ!» នាងនិយាយខ្សោយៗដោយសម្លឹងខ្ញុំតាំងពីជំហានឈានចូលដំបូង។

បេសកកម្មចំពោះមុខរបស់ខ្ញុំនៅពេលនេះ គ្មានអ្វីទាំងអស់ក្រៅតែពីប្រឹងធ្វើយ៉ាងណា ជួយឱ្យគេរឹងមាំឡើងវិញ ទម្រាំទទួលបានស្ថានភាពសុខភាពមួយ ដែលអាចថាវេជ្ជបណ្ឌិតអនុញ្ញាតឱ្យវះកាត់។

«លែងអីហើយ! កុំគិតច្រើនពេកអូនឯងនឹងជាដូចដើមវិញ!»

«បងឯងមកដល់ហើយ ខ្ញុំច្បាស់ជាបានជា!»

គេវាចាមកខ្លីៗហើយចាប់ផ្ដើមញញឹមស្វាញបង្ហាញចេញស្នាមជ្រួញដោយអន្លើរបស់គេ។

ស្នាមញញឹមរបស់គេធ្វើចិត្តខ្ញុំធូរណាស់។ ខ្ញុំមិនដឹងថា ហេតុអីបានជាមានតែការញញឹមនៃនារីម្នាក់នេះប៉ុណ្ណោះ ដែលអាចធ្វើឱ្យបេះដូងរបស់ខ្ញុំរបើកខ្សាកចាកចេញពីភាពតឹងតែងទាំងអស់នៅលើលោកនេះបាន។

ខ្ញុំបានបំភ្លេចរឿងទុក្ខវេទនា គំនុំចងអាឃាត សេចក្ដីឈឺចាប់ខ្លោចផ្សា ដែលអ្នកណាក៏ដោយបានធ្វើមកលើ គឺបំភ្លេចទាំងអស់ឱ្យតែខ្ញុំបានឃើញស្នាមញញឹមរបស់គេ។ ប្រហែលជាគេ ដឹងរឿងនេះច្បាស់ជាងមនុស្សស្រីណាទាំងអស់ ជាលូកម្រាមដៃមកកាន់ខ្ញុំ។

ម្រាមគេទាំងប្រាំទន់ល្មើយ ក្ដៅឧណ្ហៗរបស់អាមីនមកកាន់ប៉ះបាតដៃគ្រោតគ្រើមលំបាកវេទនារបស់ខ្ញុំ ដូចកាលពីយប់ដែលខ្ញុំបានគ្រាហ៍គេដោយស្រវឹងខ្លាំង ក្បែរកន្លែងចាក់សំរាមទៅកាន់ផ្ទះជួល

របស់ខ្ញុំ ក៏ជាយប់មួយដែលយើងបានជួបគ្នាឡើងវិញតែពីរនាក់ បន្ទាប់ពីខ្ញុំបានសម្រេចចិត្តចាកចេញពីជីវិតរបស់គេ ប្រគល់គេទៅឱ្យអាម៉ាច។

យប់នោះនាងអង្វរខ្ញុំយ៉ាងជូរចត់ ហាក់បីដូចជា ខ្លាចថាខ្ញុំនឹងប្រគល់នាងឱ្យត្រឡប់ទៅនៅផ្ទះជាមួយប្ដីរបស់នាងវិញ។

«ឯងមានប្ដីហើយ! ឈប់ធ្វើរឿងឡប់ៗប្រយ័ត្នគេថាឱ្យបាន! ឯងត្រូវគិតដល់យើងទាំងបីនាក់ បងគ្មានលទ្ធភាពថែរក្សាឯង គ្មានលទ្ធភាពស្អីទាំងអស់ឯងឃើញហើយ! ឯងនឹងអាម៉ាចទាំងពីរនាក់អាចថែគ្នាទៅវិញទៅមកគឺជាជម្រើសដ៏ល្អសម្រាប់ពួកយើងបីនាក់!»